# បងអប់រំខ្ញី

**ស្តីពី**: ធម្មកាលនៃព្រះពុទ្ធ

**សំណួរ**: តើធម្មកាល របស់ព្រះពុទ្ធគោតមមាន ត្រឹមតែ៥ពាន់ឆ្នាំមែនឬ?

តាំងពីបុរាណកាល រៀងមកដល់បច្ចុប្បន្នកាល ពួកពុទ្ធសាសនិកដែលគោរពប្រកាន់ជឿពុទ្ធសាសនា ថាជាសាសនាល្អឯក ជាសាសនាប្រចាំពិភពលោក ជាសាសនាឥតជាប់ទាក់ទងនឹងជាតិសាសន៍ណាមួយដោយឡែក ឥតទាក់ទងនឹងរដ្ឋឬប្រទេសណាមួយដោយឡែក ឥតជាប់ទាក់ទងនឹងពួកក្រុមពិសេសណាមួយដោយឡែក ឥតទាក់ទងនឹងការបម្រើលទ្ធិឬមនោគមវិជ្ជាណាមួយដោយឡែក ក៏ចេះតែជឿប្រកាន់គោរពទៅ ។ ចំណែកឯពួកពាហិរសាសនិកដែលគោរពជឿលទ្ធិផ្សេង គេចោទប្រកាន់ថាព្រះពុទ្ធ-

សាសនាជាសាសនា ដឹកនាំមនុស្សឲ្យប្រាសចាកប្រយោជន៍ ជាសាសនានាំមនុស្សឲ្យក្រខ្សត់ ជាសាសនាដឹកនាំមនុស្សឲ្យល្ងង់ខ្លៅ ជាសាសនាប្រឆាំងនឹងការរីកចម្រើននៃសម័យកាលក៏ចេះតែទិតៀនចោទប្រកាន់ទៅ ។

ដោយហេតុនេះ សូម្បីតែពុទ្ធសាសនិកខ្លះក៏យល់ច្រឡំផងដែរ ថាព្រះពុទ្ធសាសនា គ្រាន់តែជាសាសនាបែបប្រពៃណី ជាសាសនាសម្រាប់ឆ្លងទៅបរលោក ស្រុកខ្មោច ឬជាសាសនាសម្រាប់សូត្យ ផ្លុំ ស្តោះ កែគ្រោះ ស្រោចទឹកលើករាសី ពុំនោះសម្រាប់បែរបន់ស្រន់យកសេចក្តីសុខប៉ុណ្ណោះ ។ ម្ល៉ោះហើយ ផ្នត់គំនិតនៃអ្នកមិនចេះមិនដឹងទាំងនោះ បានជះឥទ្ធិពលពីម្នាក់ទៅម្នាក់ពីមួយទំនាន់ទៅមួយទំនាន់រហូតក្លាយទៅជាផ្នត់គំនិតសង្គមយល់ខុសតៗគ្នា ត្រាតែហួសវិស័យនៃអ្នកប្រាជ្ញធ្វើការកែប្រែបាន ។ ដើមហេតុដែលបណ្តាលឲ្យផ្នត់គំនិតខុសទំនងនេះដក់ជាប់ម៉ឹងហើយចេះតែយល់ខុសកែពុំបាននោះ ដោយហេតុពីរយ៉ាង គឺទី១ ដោយសារមត៌កវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីចាស់ៗជាយូរលង់ណាស់មកហើយ ហើយនៅតែដក់ជាប់ក្នុង

សន្តានចិត្តនៃចាស់ទុំទាំងអស់នោះ, ទី២ដោយសារកង្វះខាតការយល់ដឹងនូវគោលធម្មសាស្ត្រពិតប្រាកដ ឬបុព្វសិទ្ធិច្បាស់លាស់របស់ព្រះពុទ្ធសាសនា ។ ការដែលធ្វើឲ្យពុទ្ធសាសនិករួញរាខ្ជិលមិនចង់រេះមិនចង់យល់មិនចង់ដឹងនូវអត្ថរសនៃព្រះពុទ្ធសាសនា ដោយអាស្រ័យហេតុមានឧបសគ្គ៣យ៉ាងគឺ៖

១. ពុំដឹងថា ព្រះពុទ្ធបង្កើតធម៌ឬត្រាស់ដឹងធម៌ដូចគ្នាឬទេ ឬក៏ត្រាស់ដឹងធម៌ខុសៗគ្នា ?

២.ព្រះពុទ្ធសាសនាកើត ក្រោយសាសនាព្រាហ្មណ៍ ហេតុនេះពាក្យប្រៀនប្រដៅភាគច្រើនឬធម្មការៈ ភាគច្រើនត្រូវរំលេចតាមលំនាំលទ្ធិព្រាហ្មណ៍ ?

៣.ធម្មកាលរបស់ព្រះពុទ្ធយើងសព្វថ្ងៃនេះ មានត្រឹមតែ៥ពាន់ឆ្នាំតែប៉ុណ្ណោះ លុះអំណាស់ពីនេះទៅលែងមានព្រះធម៌ទៀតហើយ ?

ចំពោះឧបសគ្គទាំង៣នេះ យើងមានទីតិវិធីដោះស្រាយជម្រះកង្វាហេតុដូចខាងក្រោម៖

១. ព្រះពុទ្ធទាំងឡាយ ទ្រង់ពុំមែនបង្កើតព្រះធម៌ទេ គឺទ្រង់គ្រាន់តែត្រាស់ដឹងនូវបណ្តុំនៃធម្មជាតិដែលកើតមានស្រាប់តាមចង្កោមសភាវលក្ខណៈតែប៉ុណ្ណោះ ពោលគឺអ្វីណាដែលកើតមាននៅក្នុងលោកនេះ ទ្រង់គ្រប់ព្រះអង្គតែងត្រាស់ដឹងនូវហេតុបច្ច័យ ឬអស្តិភាពអ្វីនោះ, ហើយការត្រាស់ដឹងព្រះធម៌របស់ព្រះអង្គទៀតសោត មិនមានអ្វីខុសប្លែកគ្នាឡើយ គឺត្រាស់ដឹងព្រះធម៌ដូចៗគ្នាទាំងអស់,បទដ្ឋាន និរុត្តិ លក្ខណៈ កងបញ្ញត្តិ កងធម្មក្ខន្ធ ស្របគ្នា ស្មើគ្នា និងឯកភាពគ្នាបំផុត មិនសាំញ៉ាំចម្រូងចម្រាសគ្នា ដូចច្បាប់ផ្លូវលោកបច្ចុប្បន្ននេះទេ ។

២. ព្រះពុទ្ធសាសនាកើតក្រោយសាសនាព្រាហ្មណ៍ គឺក្រោយតែសាសនានៃព្រះពុទ្ធគោតមប៉ុណ្ណោះទេ មិនមែនក្រោយគ្រប់ព្រះពុទ្ធនោះទេ, ទាំងពាក្យទូន្មាន ឬធម្មភាវៈក៏អង្គព្រះគោតមត្រាស់ដឹងតពីព្រះពុទ្ធមុនៗដែរ មិនមែនទៅជ្រើសរើសយកលទ្ធិព្រាហ្មណ៍មកជារបស់ខ្លួនឡើយ ផ្ទុយទៅវិញ សាសនាព្រាហ្មណ៍ទៅវិញទេដែលតែបំបាត់លួចបន្លំយកព្រះធម៌ព្រះពុទ្ធសាសនាមកផ្សំផ្គុំពូតផ្តុំ នឹង

គោលគំនិតខ្លួន ហើយប្រកាសថាជាលទ្ធិរបស់ខ្លួនតែម្តងទៅ ឥតដឹងម៉ង់ទីទុយថាព្រះពុទ្ធសាសនាជាសាសនាដើមដំបូងរបស់ខ្លួនទេ ឯខ្លួនវិញកំពុងតែប្រព្រឹត្តគោរពប្រតិបត្តិព្រះធម៌របស់ព្រះពុទ្ធសាសនាឡើយ ។ សូម្បីលទ្ធិផ្សេងទៀតក៏ដូចគ្នាដែរ ។

៣. ធម្មកាលរបស់ព្រះពុទ្ធយើងសព្វថ្ងៃនេះ កំណត់ត្រឹមតែ៥ពាន់ឆ្នាំ គឺកំណត់យកអាណាត្តិកាលរបស់ព្រះពុទ្ធគោតម មិនមែនកំណត់យកអាយុព្រះពុទ្ធសាសនាទាំងអស់នោះទេ ។ ក៏ឯព្រះធម៌ដែលជាពាក្យប្រៀនប្រដៅនៅគង់វង្សធរមានដដែល គឺនៅមានសុចរិតធម៌ កុសលកម្មបថ១០ ព្រហ្មវិហារធម៌ សម្រាប់ទ្រទ្រង់ពិភពលោកជាដរាបពុំបានបាត់បង់ទៅណាទេ ទាស់តែថា បន្តិចៗទៅ ចេះតែលង្វែកទៅៗយូរអង្វែងណាស់ នៅពេលណាអស់អ្នកគោរពប្រតិបត្តិទើបមានព្រះពុទ្ធឬ ស្តេចចក្រពត្តិឧប្បត្តឡើងមួយព្រះអង្គ ។ សេចក្តីនេះ អាចប្រៀបធៀបទៅនឹងនីតិរដ្ឋបានតាមធម្មតា ប្រព័ន្ធគ្រប់គ្រងរដ្ឋ តែងមានអ្នកតំណាងរាស្ត្រដែលហៅថា រដ្ឋសភា, អាណាត្តិកាលមាន៥ឆ្នាំម្តង បើដល់

ពេលអស់អាណត្តិហើយ សភានេះគ្មានសុពលភាពទៀតឡើយ ត្រូវរង់ចាំសភាថ្មីមកដឹកនាំជំនួស ។ តែថា ប្រព័ន្ធច្បាប់ដែលអនុម័តកន្លងមក នៅមានអាជ្ញាយុកាលដដែល គឺប្រជានុរាស្ត្រនៅតែគោរព កោតខ្លាច ប្រព្រឹត្តអនុវត្តរហូត ពុំបានបាត់បង់ឬនិរាករទៅតាមសភាចាស់នោះទេ ។

ហេតុដូច្នេះ ធម្មកាលរបស់ព្រះពុទ្ធសាសនា នៅមានអានុភាព មានធម្មាយុកាល តាមអភិបាលរក្សាសត្វលោកជារហូត ពុំមែនចេះតែរលត់រលាយសាបសូន្យដោយឥតខ្លឹមសារ តាមអាណត្តិកាលនៃព្រះពុទ្ធគ្រប់អង្គនោះទេ៕

(ដកស្រង់សម្រួលពីអត្ថបទ ព្រះសិទ្ធត្ថោ សុង ស៊ីវ
ដោយអគ្គសិរីវិមលញ្ញាណ លី ប៊ុន លីង)